# ការសំភាសន៍របស់លោកពូ សោម ថេត

កះ  អ្នកដែរសំភាសន៍ជាង ស៊ីអ៊ារ        ខះ  អ្នកដែរអោយគេសំភាសន៍ ពូ សោម ថេត

## ការសង្ខេបរបស់លោកពូ សោម ថេត

លោកពូ សោម ថេត មានអាយុ 54ឆ្នាំ នៅក្នុងឆ្នាំ2018 លោកពូ សោម ថេត មានភេទប្រុសលោកពូ សោម ថេត មានទីលំនៅបច្ចុប្បន្ននៅភូមិដក់ពរ ឃុំរល្លីសរ ស្រុកសំរោងទង់ ខេត្តកំពង់ស្ពឺ។

កះ  ចឹងជាដំបូងខ្ញុំអរគុណច្រើនដែរពូបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ពូ ហើយការសំភាសន៍នេះត្រូវ បានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់អោយពួកយើងរក្សាប្រវត្តិរបស់លោកពូជូន ទៅកូនចៅអីចឹងណាស់ នឹងប្រវត្តិរបស់ដូនតាដើម្បីអាចស្គាល់ពីប្រវត្តិរបស់ពូអីចឹងណាស់ ហើយចឹងនៅពេលដែរពួកយើងធ្វើមួយនឹងពួកយើងនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសពូ

ខះ  បាទក្មួយនឹងហើយ

កះ  បាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍ពូខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍ពូគឺនៅថ្ងៃ ទី13 ខែ2 ឆ្នាំ2018 ចឹងពូមានឈ្មោះអីគេដែរពូ ឈ្មោះពេញរបស់ពូហាស?

ខះ  ខ្ញុំឈ្មោះ សោម ថេត

កះ  ចុះពូមានឈ្មោះហៅក្រៅទេពូ?

ខះ  អត់ទេខ្ញុំមានឈ្មោះតែមួយនឹង អត់មានឈ្មោះណាទៀតទេ

កះ  អ៎ូ!ខ្ញុំភ្លេច ខ្ញុំធ្វើការសំភាសន៍មួយនឹងនៅភូមិដក់ទរ

ខ៖ អត់ទេភូមិដក់ពរ

ក៖ ចុះឃុំអីគេដែរពូ?

ខ៖ ឃុំវល្លិ៍សរ

ក៖ ឃុំវល្លិ៍សរ ស្រុកអីគេដែរ?

ខ៖ ស្រុកសំរោងទង់ ខេត្តកំពង់ស្ពឺ

ក៖ ស្រុកសំរោងទង់ ខេត្តកំពង់ស្ពឺ ចឹងពូមានឈ្មោះពេញមិញឈ្មោះអីគេដែរពូ?

ខ៖ ខ្ញុំឈ្មោះសោម ថេត

ក៖ ដូចជាមានឈ្មោះហៅក្រៅដែរទេពូ?

ខ៖ អត់មានទេ

ក៖ អត់មានទេណាពូ?

ខ៖ ក្នុងបញ្ជីជាតិក៏ហៅឈ្មោះមួយនឹង ខាងក្រៅក៏ហៅឈ្មោះមួយនឹងដែរ

ក៖ ចុះកាលពីក្មេងធ្លាប់មាននរណាហៅឈ្មោះពូអីផ្សេងទេពូ?

ខ៖ អត់មានទេនឹង

ក៖ ចុះពូសព្វថ្ងៃពូអាយុប៉ុន្មានដែរពូ?

ខ៖ ខ្ញុំអាយុ54ឆ្នាំហើយនឹង

ក៖ ពូមានអាយុ54ឆ្នាំណាពូ ចុះពូមានដឹងថាពូកើតនៅថ្ងៃខែឆ្នាំណាដែរទេពូ?

ខ៖ ខ្ញុំចាំខ្លះ ហើយក៏ភ្លេចខ្លះដែរនឹង

ក៖ បាទពូអាចប្រាប់ថ្ងៃ ខែ ឆ្នាំពូបានទេ?

ខ៖ ខ្ញុំកើតមុនលុនណុល ខ្ញុំកើតនៅឆ្នាំ1977

ក៖ ចុះខែពូមានចងចាំដែរទេ?

ខ៖ អត់នឹងភ្លេចដែរ

កៈ ចុះពូឆ្នាំខ្មែរពូឆ្នាំអីគេដែរពូ ដូចជាឆ្នាំជូត ឆ្លូវ ខាល ថោះហាសពូឆ្នាំអីគេដែរ?

ខៈ គិតទៅដូចជាឆ្នាំរជូវច្រូតហើយនឹង

កៈ ប៉ុន្តែលក្ខណៈជូត ឆ្លូវ ខាល ថោះពូឆ្នាំអីគេដែរ?

ខៈ ឆ្នាំនឹងខ្ញុំអត់ចងចាំទេឆ្នាំនឹង

កៈ អូ៎!ពូអត់ចាំទេណាពូ?

ខៈ ប៉ុន្តែបើនិយាយពីខែវិញយើងចំខែរជូវច្រូតហើយនឹង

កៈ អូ៎!ខ្ញុំអត់ស្គាល់ដែរនឹង ចុះពូកើតនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីដែរពូ?

ខៈ ខ្ញុំនៅស្រុកភូមិនឹងដែរនឹង

កៈ ភូមិអីម្តងទៀតពូ?

ខៈ ភូមិដក់ពរ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺនឹងដែរ

កៈ ចុះពូមានបងប្អូនចំនួនប៉ុន្មាននាក់ដែរពូ?

ខៈ ខ្ញុំមានបងប្អូនចំនួន3នាក់ ប៉ុន្តែសុទ្ធប្រុសទាំងអស់នឹង

កៈ ចុះពូជាកូនទីប៉ុន្មានដែរពូ?

ខៈ ខ្ញុំជាកូនទី1

កៈ អូ៎! ចុះប្អូនៗរបស់ពូនឹងមានឈ្មោះអីគេដែរពូ?

ខៈ ប្អូនរបស់ខ្ញុំមានឈ្មោះ សោម ស៊ីថា នឹងឈ្មោះ សោម ស៊ី ថាត

កៈ ឈ្មោះសោម ស៊ីថា នឹង ឈ្មោះសោម ស៊ីថាត?

ខៈ បាទនឹងហើយត្រូវ

កៈ ចុះពូមានសាច់រឿងអីជាមួយគាត់ដែរទេពូ?

ខៈ ខ្ញុំគ្មានធ្លាប់មានសាច់រឿងអីទេ

កៈ ដូចលក្ខណៈថាពូមានលេងឡឹកបាយឡ រីលេងអីនៅផ្ទះចឹងណាស់?

ខ៖ មានប្រវត្តិដើរលេងសើចអី
ធម្មតាយើងជាបងប្អូនមានការដើរលេងសើចពេលដែរមានបុណ្យទានអី ចឹងដែរនឹងណា

ក៖ បាទពូខ្ញុំចង់និយាយមួយនឹងណាស់?

ខ៖ មានដែរតើនឹង

ក៖ ចុះពូធ្លាប់មានលក្ខណៈថាលេងបិទពួន លេងគប់ លេងស៊ីញ៉ែអីដែរទេពូ
រឺលក្ខណៈថាលេងកូនបែងអីចឹងណាស់ពូ

ខ៖ អត់ទេពីព្រោះថាអីចឹងៗខ្ញុំមិនដែរលេងជាមួយប្អូនៗទេនឹង
បើនាំប្អូនទៅលេងតាមវត្តតាមអីនឹង ចេះតែនាំប្អូនដើរទៅណាស់

ក៖ អូ៎!លក្ខណៈលេងល្បែងប្រជាប្រិយ៍អីចឹងមែនទេពូ?

ខ៖ អាលក្ខណៈថាមើលល្ខោនយីកេរ្តិ៍ អាយ៉ៃអីចឹងទៅណាស់

ក៖ អូ៎!ពូចូលចិត្តធ្វើចឹងវិញ?

ខ៖ បាទចេះតែនាំប្អូនដើរតាមវត្ត តាមអីមើលគេសើចសប្បាយអីចឹងទៅណាស់

ក៖ ចុះពូធ្លាប់មាននាំប្អូនទៅស្រែទៅចាប់ត្រីអីដែរទេ?

ខ៖ អូ៎!អានឹងប្អូនដោយប្អូន ហើយខ្ញុំគឺដោយខ្ញុំទេនឹង

ក៖ អូ៎!អត់មានទេណាពូ ចុះពូចូលចិត្តលេងអីជាមួយប្អូនពូដែរកាលពីនៅក្មេងដែរ?

ខ៖ ដើរលេងបុណ្យដើរទានអីចឹងទៅ

ក៖ អូ៎!នឹងពូចូលចិត្តដើរ លក្ខណៈលេងរាំអីនឹងណាពូ?

ខ៖ អត់ចេះរាំទេ យើងដើរមើលគេលក្ខណៈថាយើងដើរបុណ្យណាស់

ក៖ បាទពូ ចុះប្អូនរបស់ពូសព្វថ្ងៃនឹងគាត់នៅណាដែរទៅពូ?

ខ៖ គេនៅខេត្តកណ្តាលនឹង

ក៖ នៅខេត្តកណ្តាលនឹងទាំងពីរនាក់តែម្តងនឹង?

ខ៖ បាទនៅនឹង

កៈ ចុះគាត់ធ្វើអីគេដែរនៅខេត្តកណ្ដាលនឹងពូ?

ខៈ មុខរបរគាត់គឺគ្រូពេទ្យនឹង

កៈ ចុះឪពុករបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខៈ ឪពុករបស់ខ្ញុំគាត់មានឈ្មោះ សោម ស៊ុន

កៈ អូ៎!ឈ្មោះ សោម ស៊ុន ចុះគាត់អាយុប៉ុន្មានដែរពូ?

ខៈ គាត់អាយុជិតប៉ែតហើយគាត់អាយុចិតក្រាស់ហើយនឹង

កៈ ប្រហែលជាអាយុ78-79ឆ្នាំអីនឹងមែនទេពូ?

ខៈ នឹងហើយប្រហែលប៉ុណ្ណឹង

កៈ ចុះគាត់កើតនៅឆ្នាំណាពូមានដឹងទេ?

ខៈ ខ្ញុំអត់ដឹងផងនឹង

កៈ ចឹងពូមិនដឹងទេ ចុះគាត់កើតនៅភូមិណាពូមានដឹងទេពូ?

ខៈ ស្រុកកំណើតរបស់គាត់នឹងនៅខាងកើតណោះ

កៈ ចឹងឪពុករបស់ពូគាត់បានកើតនៅឆ្នាំ1948ពូ?

ខៈ បាទនឹងហើយ

កៈ ចុះគាត់ឆ្នាំអីគេដែរពូ លក្ខណះថាឆ្នាំជូត ឆ្លូវ ខាល ថោះហាសពូ?

ខៈ ខ្ញុំអត់ដឹងផងនឹង

កៈ ចឹងមានន័យថាពូមិនដឹងទេ ចុះម្ដាយរបស់ពូមានឈ្មោះអីគេដែរពូ?

ខៈ ម្ដាយរបស់ខ្ញុំគាត់មានឈ្មោះភឹម ធុន

កៈ អូ៎! ចុះគាត់អាយុប៉ុន្មានដែរពូ?

ខៈ គាត់អាយុចិតជាងដែរហើយនឹង

កៈ ចុះយាយគាត់ប្អូនតាប៉ុន្មានឆ្នាំដែរនឹង?

ខ៖ គាត់មិនដឹងថាប្អូនតាប៉ុន្មាននោះទេ បើគាត់នៅប្រហែលជាចិតស្តើងដែរនឹង

ក៖ ចុះយាយគាត់កើតនៅណាដែរពូ?

ខ៖ យាយស្រុកគាត់នៅនឹង

ក៖ ចុះតាគាត់ធ្វើអីគេដែរពូ ដូចថាគាត់ធ្វើអីសំរាប់ចិញ្ចឹមជីវិត?

ខ៖ គាត់ធ្វើតែស្រែ នឹងចំការនឹងនឹងឡើងត្នោតចឹងទៅ

ក៖ ចុះគាត់មានធ្វើអីផ្សេងទៀតទេពូ?

ខ៖ គាត់មិនដែរធ្វើអីទេនឹង

ក៖ ចុះគាត់ជាមនុស្សស្លូត រឺមួយក៏កាចដែរពូ?

ខ៖ គាត់ស្លូតណាស់

ក៖ ចុះយាយសព្វថ្ងៃនឹងយាយក៏នៅរស់នឹងដែរណាពូ?

ខ៖ សំរាប់យាយក៏គាត់រស់ដែរនឹង

ក៖ ប៉ុន្តែយាយគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរ?

ខ៖ ឥឡូវនឹងគាត់ចាស់ហើយគាត់ទ្រុឌទ្រោមអោយគាត់

ក៖ អូបាទពូត្រូវហើយនឹង?

ខ៖ ហើយសំរាប់គាត់ក៏ធ្វើអាចារ្យវត្តអីដែរចឹងណាស់

ក៖ ប៉ុន្តែយាយស្លូតរឺមួយក៏កាចដែរពូ?

ខ៖ យាយគាត់ស្លូតទេ និយាយទៅយាយតាគាត់ស្លូតៗទេនឹង

ក៖ ប៉ុន្តែឥឡូវនឹងយាយតានៅជាមួយពូមែនពូ?

ខ៖ អត់ទេផ្ទះគាត់នៅផ្សេងៗពីខ្ញុំនឹង

កៈ
ប៉ុន្តែពូមានចងចាំថាកាលពីពូនៅជាមួយគាត់ពូមានធ្លាប់បានធ្វើអីគេខ្លះជាមួយឪពុកម្ដាយពូដែរ?

ខៈ ខ្ញុំគ្រាន់តែជួយធ្វើស្រែចំការចឹងឯង

កៈ
ប៉ុន្តែពូមានធ្លាប់មានចងចាំអនុស្សាវរីយ៍អីជាមួយគាត់ដូចថាលេងអីជាមួយតាយាយទេ?

ខៈ អត់មានទេ ដឹងតែទៅរើនពេលមកពីរៀនវិញជួយធ្វើការងារគាត់ចឹងទៅ

កៈ ប៉ុន្តែមិនដែរនាំពូអីដើរលេងទេណាពូ?

ខៈ ដូចថាខែបុណ្យទានអីគាត់ហៅកូនចៅទៅបុណ្យទានដែរនឹង

កៈ គាត់ធ្លាប់នាំពូទៅដែរហោសពូ?

ខៈ គាត់ធ្លាប់តើនឹង

កៈ ចុះតាយាយគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅពូដែរទេ?

ខៈ គាត់ធ្លាប់ប្រាប់ដែរតើ ជីវប្រវត្តិរបស់ឪរបស់ខ្ញុំនឹង

កៈ ពូអាចចែកចាយខ្លះៗបានទេ?

ខៈ កូនគាត់ថាគាត់ផ្ដែផ្ដាំទៅកូនចៅថាកូនៗទាំងអស់គ្នាខំយកចំនេះវិជ្ជា
ខំរៀនខំសូត្រទៅណាស់ ពីព្រោះតែជីវប្រវត្តិរបស់គាត់ក្រ
ឪក្រហើយឪកំព្រាតាំងពីឪនៅបីទទឹងណាស់

កៈ អូ៎!គាត់និយាយចឹងណាពូ?

ខៈ គាត់និយាយអោយកូនខំរៀនសូត្រចឹងទៅ នឹងកាលខ្ញុំនៅរៀន
ហើយឪក៏គាត់ធ្វើស្រែចំការចឹងទៅ
បើជីវប្រវត្តិរបស់ឪរបស់ខ្ញុំបើគាត់និយាយសឹងតែស្រក់ទឹកភ្នែក

កៈ អូ៎!រឿងគាត់កំសត់ណាពូ?

ខ៖  កាត់ថាម្ដាយគាត់ស្លាប់ហើយគាត់ម្ដាយស្លាប់តាំងពីគាត់នៅបីទទឹង
ហើយគាត់បានរស់មកដល់
ថ្ងៃនេះនឹងដូចថាមិត្តនៅក្នុងភូមិគាត់បានដឹងពីជីវប្រវត្តិម៉ែរបស់គាត់ចឹងណាស់ម្ដាយគាត់ស្លួតចឹងទៅគេ ក៏បានយកគាត់ទៅចិញ្ចឹម

ក៖  អូ៎!ជូចត់ប្រវត្តិរបស់គាត់ពូ?

ខ៖  គេយកគាត់ទៅចិញ្ចឹម គាត់ស៊ីឈ្នួលគេដើរឃ្វាលគោ
ដើរធ្វើអីចឹងទៅណាស់ហើយបានគាត់រៀន
ចឹងទៅបានគាត់ចេះដឹងអីចឹងបានគាត់ទៅនៅវត្តអីចឹងទៅណាស់

ក៖  ចឹងបានគាត់ទៅនៅវត្តមែនទេពូ?

ខ៖
នឹងហើយបានទៅនៅវត្តចឹងទៅបានយាយៗតាៗគេទៅបំបួសអោយគាត់ចឹងទៅបានគាត់បានរៀន

ក៖  ប៉ុន្តែគាត់ទៅបួសនៅណាដែរ?

ខ៖  គាត់ទៅបួសនៅវត្តយើងនៅជិតព្រែកផ្ដៅយើងនឹង

ក៖  ចុះគាត់ទៅបួសនឹងគាត់អាយុប៉ុន្មានឆ្នាំដែរពូ?

ខ៖  គាត់ទៅបួសនឹងខ្ទង់គាត់អាយុ14-15ឆ្នាំនឹង

ក៖  អូ៎!គាត់បួសនឹងគាត់នៅក្មេងពូ?

ខ៖  គាត់បួសតាំងពីគាត់នៅតូចនឹង
ដល់ពេលដែរគាត់សឹកពីបួសវិញបានគាត់ទៅនៅជាមួយម៉ែចិញ្ចឹម របស់គាត់នឹង

ក៖  ពេលណុងគាត់ទៅនៅជាមួយម៉ែរបស់គាត់វិញទៅ?

ខ៖  នឹងហើយគាត់ក៏ទៅស៊ីឈ្នួលគេនៅទន្លេ គាត់ធ្លាប់និយាយប្រាប់កូនៗចឹងទៅណាស់

ក៖  នឹងប្រវត្តិរបស់គាត់?

ខ៖  គាត់ផ្ដែផ្ដាំថាកូនអើយខំប្រឹងរៀនសូត្រទៅ ខំប្រឹងរកចឹងទៅ កុំអោយដូចឪ ឪកើតមកមិនបានស្គាល់ ម្ដាយឪពុកទេនឹង

ក៖  អូ៎!ចឹងមានន័យថាគាត់មិនទាន់ម្ដាយឪពុករបស់គាត់ទេណាពូ?

ខ៖  គាត់មិនទាន់ទេ បងគាត់ទើបតែចេះដើរតិចៗទេ ដល់ពេលគាត់នៅបីទទឹងនឹង គាត់នៅបីទទឹងដូច ចៅរបស់ខ្ញុំចឹងណាស់

ក៖  អូ៎!គាត់នៅតូចៗណាពូ?

ខ៖  នឹងហើយនៅតូចៗនឹង នឹងជីវប្រវត្តិគាត់ដែរគាត់បានប្រាប់

ក៖  ប៉ុន្តែយាយគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាតដែរទេ?

ខ៖  យាយគាត់ធ្លាប់ប្រាប់ដែរគ្រាន់តែយាយវាមិនកំសត់ដល់តា

ក៖  ចឹងតាកំសត់ជាងពូ?

ខ៖  នឹងតាកំសត់ជាង

ក៖  ចុះយាយតាខាងឪពុកនឹងពូមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖  យាយតាហោស?

ក៖  ដូចជាយាយតាខាងឪពុករបស់ពូទៀតណាស់?

ខ៖  បើតាខាងឪពុករបស់ខ្ញុំឈ្មោះ សំ

ក៖  នឹងតាខាងឪពុករបស់ពូ ចុះយាយវិញ?

ខ៖  យាយឈ្មោះភឹម

ក៖  ចុះពូមានចងចាំថ្ងៃគាត់កើតនៅឆ្នាំណាដែរទេពូ?

ខ៖  អត់ដឹងទេ

ក៖  ប៉ុន្តែតាយាយគាត់កើតនៅឆ្នាំណាពូមានដឹងទេ?

ខ៖  ខ្ញុំមិនបានដឹងទេ បើមិនដែរសួរនាំគាត់ផងនឹង

កៈ ចុះគាត់កើតនៅណាក៏ពូមិនដឹងដែរណាពូ?

ខៈ បាទមិនដឹងទេ

កៈ ចុះយាយតាខាងម្ដាយពូ?

ខៈ យាយតាខាងម្ដាយគាត់កើតនៅនឹង

កៈ ប៉ុន្ដែគាត់មានឈ្មោះអីគេដែរពូ?

ខៈ យាយតាគាត់ទៀតហោស?

កៈ អត់ទេយាយតាខាងម្ដាយហាស?

ខៈ អ៎ូ!ធ្លាប់លឺចាស់ៗនិយាយដែរនឹង តាឈ្មោះតាផាន់ យាយឈ្មោះយាយថន

កៈ ប៉ុន្ដែយាយតាគាត់កើតនៅនឹងខាងម្ដាយណាពូ?

ខៈ បាទនៅនឹង

កៈ ប៉ុន្ដែគ្រួសារពូនៅខេត្តនឹងយូរនៅពូ?

ខៈ គ្រួសារខ្ញុំនៅខេត្តកំពង់ស្ពឺនឹងតា

កៈ ប៉ុន្ដែនៅនឹងរហូតតែម្ដងហោសពូ?

ខៈ បាទនៅនឹងរហូតនឹង

កៈ ចឹងមានន័យថាពូនៅនឹងអស់ជាង50ឆ្នាំជាង?

ខៈ នឹងខេត្តនឹងប៉ុន្ដែនៅភូមិឃុំផ្សេងគ្នា

កៈ ប៉ុន្ដែពូនៅនឹងអស់ប្រហែលជា50ឆ្នាំជាងហើយណាពូ?

ខៈ បាទតាំងពីកើតដឹងក្ដីមកខ្ញុំនៅតែនឹងទេ

កៈ ចឹងពូអត់មានផ្លាស់ទៅនៅណាផ្សេងទៀតទេណាពូ?

ខៈ អត់មានទេ យើងផ្លាស់នឹងពេលដែរសម័យអាពតនឹង
ដល់ពេលដែរចប់ពីអាពតនឹងខ្ញុំនៅស្រុកភូមិ នឹងរហូតនឹង

កៈ ចុះពូមានកូនចៅ រឺមួយបងប្អូនណាដែររស់នៅក្រៅប្រទេសទេ?

ខៈ អត់មានទេ

កៈ នៅវៀតណាម ថៃ នៅជប៉ុន កូរ៉េអីក៏អត់មានដែរ?

ខៈ អត់មានទេ មានតែនៅខ្មែរនឹង

កៈ ចុះភរិយារបស់ពូមានឈ្មោះអីគេដែរពូ?

ខៈ គាត់មានឈ្មោះ មឹង កុសល

កៈ ឈ្មោះ មឹង កុសល ចុះពូមានចងចាំថ្ងៃដែរពូរៀបអាពាហ៍ពិពាហ៍ជាមួយមឹងដែរទេ?

ខៈ ខ្ញុំចាំដែរតើ

កៈ នៅថ្ងៃ ខែឆ្នាំណាដែរពូ?

ខៈ ខ្ញុំចាំតែឆ្នាំ ទេបើខែបើមិនខែពីរទៅខែបីនឹង

កៈ ប៉ុន្តែឆ្នាំនៅឆ្នាំណាដែរពូ?

ខៈ ខ្ញុំការនៅឆ្នាំ1990

កៈ ចឹងពូការអស់រយះពេល28ឆ្នាំណាពូ?

ខៈ បាទជាង20ឆ្នាំហើយនឹង

កៈ ចុះពេលដែរពូរៀបអាពាហ៍ពិពាហ៍នឹងដូចជាឪពុកម្តាយពូជាអ្នករៀបអោយ រឺមួយក៏ពូជាអ្នកដោយចិត្តឯងពូ?

ខៈ ម្តាយឪពុកជាអ្នករៀបអោយនឹង

កៈ ដូចជាមានជាថ្លៃទឹកដោះទេពូ?

ខៈ មានដែរតើ

កៈ ដូចជាអស់ប្រហែលជាប៉ុន្មានពូមានដឹងទេ?

ខ៖  កាលពីជំនាន់ណុងលុយនៅថ្លៃដែរនឹង អស់ខ្ទង់ប្រហែលជា1000រៀល បើយើងគិតជាលុយឥឡូវនឹង ប្រហែលជា1000$

ក៖  ប៉ុន្តែដោយសារតែលុយវាថ្លៃដែរណោពូ?

ខ៖  គ្រាន់ថាលុយវាថ្លៃជាងឥឡូវនឹង លុយយើងឥឡូវនឹងដូចថាបើមានមួយម៉ឺនយើងដកតែមួយពាន់ ទៅពីពាន់

ក៖  ពូងាចប្រាប់ខ្ញុំបានទេថាពូស្គាល់មីងបានប៉ុន្មានឆ្នាំ ហើយពូចូលស្ដីដណ្ដឹងមីងនៅពេលណា ហើយអស់រយះពេលប៉ុន្មានឆ្នាំបានពូចូលស្ដីដណ្ដឹងមីងចឹងណាស់?

ខ៖  ខ្ញុំស្គាល់តាមរយះម៉ែឪដែរគាត់គិតគូរ

ក៖  ប៉ុន្តែពូស្គាល់រយះពេលប៉ុន្មានដែរបានពូចូលស្ដីដណ្ដឹងមីង?

ខ៖
ស្គាល់បានបួនទៅប្រាំខែដែរនឹងបានម៉ែឪគាត់រៀបចំទុកដាក់ហើយគាត់បង្ហាញអោយឃើញចឹងទៅ

ក៖  ប៉ុន្តែទាំងខាងប្រពន្ធរបស់ពូ នឹងខាងពូគេស្របគ្នាហើយណាពូ?

ខ៖  បាទគេយល់ស្របគ្នាដែរនឹង

ក៖ ចុះពូមានចេះអាន រឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរពូ?

ខ៖  ខ្ញុំចេះបានតិចតួចដែរក្មួយ ខ្ញុំរៀនបានតិចដែរនឹង

ក៖  ពូរៀនបានថ្នាក់ទីប៉ុន្មានដែរពូ?

ខ៖  ខ្ញុំរៀនបានថ្នាក់ទី8នឹង

ក៖  ចុះកាលពីពូរៀននឹងតើពូរៀននៅសាលាណាដែរពូ?

ខ៖  ខ្ញុំរៀននៅសាលាចំបកនឹង

ក៖  អូ៎!នៅចំបកយើងនៅលើនឹងហោស ប៉ុន្តែនៅខេត្តនឹង?

ខ៖ នៅខេត្តនឹង

ក៖ ប៉ុន្តែសាលាមានឈ្មោះអីគេដែរពូ?

ខ៖ សាលាឈ្មោះសាលាចំបកចឹងតែម្តងនឹង

ក៖ ចឹងពូមានប្តូរសាលាទៀតទេ?

ខ៖ អត់មានទេ

ក៖ ចុះសាលាបឋមពូរៀននៅណាដែរ?

ខ៖ សាលាបឋមរៀននៅអាផ្លូវយើងចុះមកនឹង

ក៖ ប៉ុន្តែសាលាមានឈ្មោះអីគេដែរពូ?

ខ៖ ឈ្មោះសាលាទួលស្វាយរដ្ឋ

ក៖ អូ៎!ឈ្មោះសាលាទួលស្វាយរដ្ឋ ចុះពូមានចេះភាសាអីក្រៅពីភាសាខ្មែរទេពូ?

ខ៖ ខ្ញុំចេះតែខ្មែរនឹង
ភាសាផ្សេងចេះតិចតួចដែរចុះកាលពីជំនាន់ណុងគេរៀនមិនដូចយើងសេរីទេ

ក៖ បាទត្រូវមែនពូ?

ខ៖ កាលពីជំនាន់ណុងគេរៀនភាសាមិនបានដូចក្មេងរៀនសម័យឥឡូវនឹងទេ

ក៖ ក្មេងសម័យឥឡូវនឹងចង់រៀនអីក៏បានដែរសេរី?

ខ៖ ក្មេងសម័យឥឡូវនឹងស្រួលណាស់
ចង់បានអីបានណុងកាលពីជំនាន់ពូសូម្បីតែកាតាបក៏អត់មានដែរ ហើយកាន់តែសៀវភៅ
ហើយគ្មានកងជិះផងដើរទៅរៀននឹង

ក៖ បាទពូពិបាកជាងឥឡូវនឹងស្អីក៏មានដែរ?

ខ៖ នឹងហើយហើយបើថាទៅរៀនចេញពីភូមិទៅសាលាទួលស្វាយរដ្ឋនឹងឆ្ងាយដែរនឹង
ហើយបើចេញពី ភូមិទៅសាលាចមបកឆ្ងាយទៀតដីប្រហែលជា4-5គីឡូ

ក៖ អូ៎!ឆ្ងាយដែរនឹង?

ខ៖ ហើយដើរទៅរៀននឹងយើងតស៊ូបានតិចតួចនឹងបើយើងជាអ្នកស្រែនឹង

ក៖ ប៉ុន្តែគេមិនអោយយើងរៀនភាសាថៃ វៀតណាមអីទេណាពូ?

ខ៖ កាលពីជំនាន់ពូអត់មានទេ

ក៖ ចុះពូធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាដែរទេពូ?

ខ៖ មិត្តភក្តិដែររៀនមកជាមួយគ្នានឹង

ក៖ បាទពូកាលពីនៅក្មេងហាសពូ?

ខ៖
ឥឡូវនឹងគេបានធ្វើការងារធំដុំអស់ទៅគេបានប្រពន្ធទៅឆ្ងាយៗមិនដឹងថាគេយ៉ាងម៉េចទេនឹង

ក៖ ប៉ុន្តែពូមានចងចាំឈ្មោះពួកគាត់ដែរទេ?

ខ៖ អ៎ូ!អត់មានទេពួកគេសុទ្ធតែទៅស្រុកក្រៅៗអស់ហើយនឹង

ក៖ ប៉ុន្តែពូមានធ្លាប់ចងចាំដែរទេ ថាពូធ្លាប់បានធ្វើអីគេទេកាលពីពូនៅក្មេងៗហាសពូ?

ខ៖ ខ្ញុំធ្លាប់ទៅសាលាទៅអី ខ្ញុំធ្លាប់ធ្វើពលកម្មអីជាមួយគ្នាដែរនឹង
គ្រូអោយធ្វើពលកម្មអីយើងធ្វើនៅ ជាមួយគ្នាចឹងទៅ
ហើយចេះតែលេងសើចជាមួយគ្នាចឹងទៅ

ក៖ ចុះពូធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរទេពូ?

ខ៖ កាលពីជំនាន់ណុងពូទៅច្រូតស្រូវអីដែរនឹង

ក៖ កាលពីជំនាន់ណាពូ?

ខ៖ ជំនាន់យើងគុមន្នីស៍នឹងណាស់ពេលដែរយើងចុះពីអាពតមកវិញនឹង

ក៖ ចុះពូមានធ្លាប់បើកកសិដ្ឋានចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក គោក្របីអីចឹងពូ?

ខ៖ ធ្លាប់ចិញ្ចឹមគោ
ចិញ្ចឹមមាន់អីដែរប៉ុន្តែយើងចិញ្ចឹមលក្ខណៈជាគ្រួសារអីបន្តិចបន្តួចអីចឹងទៅ

កៈ អ៎ូ!ចិញ្ចឹមលក្ខណៈគ្រួសារណាពូ?

ខៈ បាទចិញ្ចឹមចឹងឯង

កៈ ប៉ុន្តែពូធ្លាប់មានបើកអាជីវកម្មលក់ដូរអីទេ?

ខៈ កាលពីដើមមកខ្ញុំមិនដែរទេ ដល់ពេលឥឡូវនឹងស្រីៗគេមកលក់នំុបន្តិចបន្តួចដែរនឹង

កៈ គាត់លក់អីគេដែរពូ?

ខៈ មានលក់ចេកចៀន មានលក់នំុប៉័ងចៀនអីចឹងទៅ

កៈ អ៎ូ!ចឹងពូលក់ចេក នឹងនំុប៉័ងចៀនណាពូ?

ខៈ បាទកាលពីក្មេងមកមិនដែរលក់អីទេនឹង

កៈ ពូធ្វើស្រែនឹងចំការណាពូ?

ខៈ បាទធ្វើតែស្រែនឹងចំការទេ នឹងចិញ្ចឹមគោអីនឹង

កៈ ចុះពូតាំងពីក្មេងពូធ្លាប់ធ្វើការងារអីគេខ្លះដែរពូ?

ខៈ កាលពីក្មេងខ្ញុំធ្វើស្រែចំការ នឹងខ្ញុំរត់រទេះសេះអីនឹង

កៈ ដល់ពេលហើយ......?

ខៈ ដល់ពេលចឹងខ្ញុំរកជួញដូរគោ ដល់ពេលដែរអស់ពីគោចឹងទៅ
ដល់ពេលឥឡូវនឹងខ្ញុំក៏ធ្វើជាសំណង់អី បន្តិចបន្តួចអីចឹងទៅ

កៈ អ៎ូ!ពូធ្វើច្រើនណាពូ?

ខៈ បាទធ្វើច្រើនណាស់

កៈ
ចុះពូគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះជីវិតរបស់ពូមានការផ្លាស់ប្តូរអីគេខ្លះដែរពូ?

ខៈ ហ៎ា! វារឿងប្លែកៗគ្នាដែរថារបស់យើងរកមកវាថ្លៃៗដែរនឹងចឹងវាចង់ទិញអីវាឆាប់បាន
តែដល់ពេលឥឡូវនឹងលុយវាថោកចឹងមិនសូវបានទិញអីប៉ុន្មាន
នឹងបើនិយាយទៅបានតែមួយហូបៗសឹងតែមិនបាន គ្រប់គ្រាន់ផង

ក៖ លក្ខណៈថាបានតែមួយទប់ៗនឹងហោស?

ខ៖ នេះនិយាយទៅយើងរកអ្នកដៃរមានកំលាំងណាស់អូន
អោយតែយើងបានតំរិះតិចតួចទៅយើងរក ដោយកំលាំងហើយនឹង

ក៖ អូ៎!ចឹងយើងប្រើកំលាំងដើម្បីដូរយកលុយវិញហោសពូ?

ខ៖ ប្រើដោយញើសឈាមចឹងទៅ

ក៖ ចុះពូគិតថាម្ហូបអីដែរពូចូលចិត្តពិសារហោសពូ?

ខ៖ ខ្ញុំចុលចិត្តតែស្លម្ជូរអីនឹងក្រៅពីនិងមិនសូវចូលចិត្តនឹង

ក៖  ចុះសំលការី កកូរវិញពូចូលចិត្តទេ?

ខ៖ មិនសូវចូលចិត្តទេ

ក៖ ចុះឆា ចៀន អាំងវិញពូ?

ខ៖ ឆា ចៀន អាំងជារឿងធម្មតាទេ

ក៖ លក្ខណៈបំពងត្រីអីពូចូលចិត្តទេ?

ខ៖ នឹងជារឿងធម្មតានឹង

ក៖ ចុះល្បែងប្រជាប្រិយ៍អីដែរពូគិតថាពីចូលចិត្តលេងតាំងពីក្មេងហាពូ ដូចជាចោលឈូង
ទាញព្រាត លាកកន្សែង?

ខ៖ នឹងទាល់តែខែយើងរដូវហោស

ក៖ ប៉ុន្តែពូចូលចិត្តលេងអីជាងគេដែរ?

ខ៖ នឹងខ្ញុំចូលចិត្តលាកកន្សែងក៏ធ្លាប់ បិទពួនអីក៏ធ្លាប់ដែរនឹង
ប៉ុន្តែគ្រាន់តែគ្រាន់តែថាវាមានខែរដូវដូចជា ខែចូលឆ្នាំអីចឹងទៅ

ក៖ ចុះតាំងពីក្មេងពូធ្លាប់បានរៀនច្រៀងទេពូ?

ខ៖ អត់បានទេ

ក៖ ចុះពូចេះច្រៀងទេ?

ខ៖ អត់ចេះទេ

ក៖ អត់ចេះទេ ប៉ុន្តែពូចូលចិត្តស្តាប់បទចំរៀង?

ខ៖ បាទបើចាក់ចឹងទៅចេះតែស្តាប់ហើយនឹង

ក៖ ប៉ុន្តែលក្ខណះបទសម័យ រឺមួយក៏បទបុរាណដែរពូចូលចិត្តស្តាប់ហាសពូ?

ខ៖ ចូលចិត្តតែបទបុរាណទេនឹង

ក៖ បទបុរាណណាពូ?

ខ៖ បទសម័យឥឡូវនឹងខ្ញុំមិនសូវចូលចិត្តទេនឹង

ក៖ ចុះពូមាននរណាគេនៅក្នុងផ្ទះរបស់ពូចេះលេងឧបករណ៍ភ្លេងដែរទេពូ?

ខ៖ កូនចៅរបស់ខ្ញុំអត់ចេះទេ

ក៖ ចុះបងប្អូនវិញពូ?

ខ៖ អត់ទេបងប្អូនរបស់ខ្ញុំក៏អត់ចេះដែរ

ក៖ ចុះផ្ទះរបស់ពូមានលក្ខណះបែបណាដែរពូតាំងពីក្មេងរហូតមកដល់ពេលនេះហាស ដូចថាពីក្មេងនឹង ផ្ទះយ៉ាងម៉េច ហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងណាស់ពូ?

ខ៖ កាលពីក្មេងខ្ញុំនៅជាមួយឪពុកម្តាយ
ខ្ញុំនៅផ្ទះខ្ទមតូចហើយជញ្ជាំងប្រកស្លឹកនឹងកាលពីខ្ញុំនៅមិនទាន មានប្រពន្ធ កូនទេ

ក៖ នឹងពេលពូមិនទានបានរៀបការ?

ខ៖ នឹងហើយដល់ពេលខ្ញុំធំឡើងចឹងទៅក៏បានធ្វើផ្ទះនៅចឹងទៅ
ហើយដល់ពេលដែរខ្ញុំការហើយក៏បានផ្ទះបែកពីគាត់ចឹងទៅក៏នៅផ្ទះខ្ទមតូចចឹងទៅណាស់
ហើយយើងចេះតែរកតិចៗចឹងទៅក៏បានផ្ទះប៉ុណ្ណឹង នៅចឹងទៅណាស់
ដល់មកសព្វថ្ងៃនឹង

ក៖ តែឥឡូវនឹងផ្ទះមួយនេះនឹងមែនពូ?

ខ៖ នឹងហើយនឹង

កៈ ដូចជាមានផ្ទះឈើ?

ខៈ បាទផ្ទះឈើនឹង

កៈ ប៉ុន្តែនរណាគេជាអ្នកធ្វើផ្ទះមួយនឹងពូ ដូចជាពូជួលគេរឺក៏ពូធ្វើដោយខ្លួនឯងដែរពូ?

ខៈ ខ្ញុំជួលគេ

កៈ ប៉ុន្តែពូមានចេះធ្វើផ្ទះទេពូ?

ខៈ ពូចេះដែរប៉ុន្តែគ្រាន់តែពូកូនជាងគេ

កៈ អូ៎!ពូជាកូនជាងហោស ប៉ុន្តែនរណាគេជាអ្នកបង្រៀនអោយពូចេះធ្វើខ្លះៗដែរពូ?

ខៈ ចាស់ៗនៅក្នុងស្រុកនឹងប៉ុន្តែគាត់ស្លាប់បាត់អស់ហើយនឹង គាត់សួរថាចេះវៃដែកគោល នឹងចេះកាន់ ពូថៅអីទេ

កៈ ហើយពូប្រាប់គាត់ថាម៉េចទៅ?

ខៈ ខ្ញុំថាអត់ចេះទេចុះដំបូងមានចេះណា យ៉ាងណាខ្ញុំធ្លាប់ឡើងលេងចឹងទៅណាស់ ហើយគាត់ថាអោយតែឯងពូកែឡើងលេងថាបើវៃដែកគោលពុងតែវៃកើតដូចតែគ្នាទេ ហើយគាត់បានហៅខ្ញុំទៅបង្ហាត់ទៅបង្រៀនតិចតួចចឹងទៅ

កៈ ចុះពូគិតថាផ្ទះរបស់ពូដែរនៅនឹងគិតថាគេប្រើឧបករណ៍គេខ្លះដែរសំរាប់ប្រើនឹងពូ?

ខៈ ប្រើរណា ពូថៅ ប្រើម៉ូទ័រអីនឹង

កៈ មានដែកគោលអីដែរតើពូ?

ខៈ នឹងហើយមានដែកគោលអីនឹង មានបាឡុងចាប់អីនឹងណាស់

កៈ ចុះដំបូលធ្វើពី..........?

ខៈ ដំបូលខ្ញុំធ្វើស៊ីបប្រូនឹង

កៈ អូ៎!ស៊ីបប្រូហោសពូ?

ខៈ ប្រើស៊ីប្រូនឹងគេមិនបាច់វៃដែកគោលដូចពីជំនាន់មុនទេនឹង យើងវៃទំពួកហាសដែវានឹងមានរាងស្ពើង ប្រហែលជាមួយទឹកអីនឹង

កៈ  អូ៎!មួយនឹងល្អជាងពីមុនណាពូ?

ខៈ  នឹងហើយភាគច្រើនខ្ញុំវែជាប់ជាមួយទំពូក

កៈ  ប៉ុន្តែមិនមែនស័ង្កសីទេណាពូ?

ខៈ  មិនមែនទេ នឹងបើខែនឹងវាក្តៅខ្លាំងដែរនឹង

កៈ  ចឹងអត់ដូចគ្រឿងទេណាពូ?

ខៈ  អត់ទេ សូម្បីតែគ្រឿងក៏នៅតែក្តៅដែរ?

កៈ  អូ៎!ចឹងគ្រាន់តែអានេះវាថ្មី?

ខៈ  ប៉ុន្តែដល់ពេលខែត្រជាក់គឺត្រជាក់តែម្តងនឹង

កៈ  ប៉ុន្តែពូអត់មានប្រើពីដានមកបិទគ្របទេអី?

ខៈ  អត់មានទេ ផ្ទះរបស់ខ្ញុំចំហអត់មានប្រើពីដានទេ

កៈ  ចុះគិតថាជំនាញអីដែរពូគិតថាពូចេះស្ទាត់ជំនាញដែរពូ?

ខៈ  ស្ទាត់ជំនាញនឹងមានតែស្រែនឹង

កៈ  ពូធ្វើស្រែ?

ខៈ  នឹងហើយមានតែធ្វើស្រែចំការនឹងហើយដែរច្បាស់ជាងគេនឹង

កៈ  ចុះម្តាយឪពុករបស់ពូគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅពូទេ ដូចជាកូរស្កត្នោត វេញវល្លិ៍ រឺមួយក៏ធ្វរជាល្អីចឹង?

ខៈ  អានឹងពីដើមឡើយនឹងម៉ែឪគាត់ឡើងដើមត្នោតខ្ញុំមិនសូវចេះតែឪទេដែរចេះ តែខ្ញុំជួបវែកទឹកត្នោត ជួយវេចត្នោតចឹងចេះតែជួយគាត់ទៅ នឹងវេញខ្សែគោអីចឹងទៅ

កៈ  អូ៎!វេញខ្សែគោពូចេះណាពូ?

ខៈ  បាទនឹងចេះ ប៉ុន្តែបើថាជំនាញដូចក្មេងៗឥឡូវនឹងមិនចេះដូចគេទេ ហើយយ៉ាងណាមួយវប្បធម៌ខ្ញុំ នឹងក៏វារៀងខ្សោយជាងគេដែរនឹង យើងរៀនបានបន្តិចបន្តួចនឹង កាលពីជំនាន់ណុងយើងវាខ្វះខាត

ក៖ យើងក៏ធ្វើតាមលទ្ធភាពយើងទៅ?

ខ៖ នឹងហើយយើងធ្វើតាលទ្ធភាពយើងនឹង

ក៖ ចុះពូអាចប្រាប់ខ្ញុំពីការលំបាកតាំងពីក្មេងរហូតមកដល់ពេលនេះបានទេពូ ដូចជាពីក្មេងនឹងពូធ្លាប់ជួបអីគេខ្លះ ហើយឥឡូវនឹងពូធ្លាប់ជួបអីគេដែរ?

ខ៖
បើនិយាយពីការលំបាកវិញនឹងអូនអើយវេទនាណាស់យើងចុះពីសម័យខ្មែរក្រហមមកនឹង

ក៖ ចុះកាលពីក្មេងពូគិតថាពូធ្លាប់ជួបការលំបាកអីគេដែរទៅពូ?

ខ៖ បាទវាធ្លាប់ជួបការលំបាកដែរតើ
ដូចថាក្រុមគ្រួសាររបស់យើងមានភាពទីទល់ក្រណាស់ ចឹងយើងខំទាំងភ្លៀងទាំងរលឹម ទាំងក្តៅចឹងទៅចេះតែទ្រាំធ្វើស្រែ ធ្វើចំការអីចឹងទៅអានឹងវាលំបាកពេល
ដែរខ្ញុំនៅស្រែវាលំបាកប៉ុណ្ណឹង

ក៖ ចុះជំនាន់ពលពតវិញពូ?

ខ៖ រហូតមកដល់ជំនាន់ពលពតនឹងរហូតមកដល់ទៀតនឹង
មកដល់សម័យយើងគុមន្ទីស៍នឹងរហូតមក ដល់សម័យយើងនឹងណាស់

ក៖ ចុះកាលពីជំនាន់ពលពតពូមានការលំបាកខ្លះបានទេថាពូជួបអីគេខ្លះដែរ?

ខ៖ សម័យពលពតគេអោយខ្ញុំកាប់ដីដំបូក អោយខ្ញុំរែកដីហើយនឹងឃ្វាលគោចឹងទៅ

ក៖ ប៉ុន្តែពូធ្វើនៅណាដែរ?

ខ៖ នេះធ្វើនៅភូមិចំការរដ្ឋយើងនេះ

ក៖ អ្ហូ!គេជំលាសពូនៅជិតៗនឹងទេណាពូ?

ខ៖ គេជំលាសខ្ញុំទៅឆ្ងាយដែរ ដល់ពេលហើយគេក៏បញ្ជូនខ្ញុំមកភូមិចំការរដ្ឋវិញនឹងដដែរ

ក៖ ប៉ុន្តែពេលណុងពូទៅម្នាក់ឯងរឺយ៉ាងណាដែរពូ?

ខ៖ ខ្ញុំទៅជាមួយឪពុកម្តាយនឹង

កៈ អូ៎!ទៅជាមួយក្រុមគ្រួសារតែម្តងហោសពូ?

ខៈ បាទទៅជាមួយក្រុមគ្រួសារខ្ញុំនឹង

កៈ ប៉ុន្តែទៅធ្វើការនឹងគេអោយពូទៅម្នាក់រឺយ៉ាងណាដែរពូ?

ខៈ ទៅចឹងមានក្រុមមានបក្សមានពួក

កៈ ប៉ុន្តែមិនមែនជាក្រុមគ្រួសារទេ?

ខៈ បាទមិនមែនជាក្រុមគ្រួសារទេ ឧទាហរណ៍ថាមានក្មេងមួយចំនួន10-20នាក់ចឹងទៅមានចាស់ម្នាក់ ទៅពីរនាក់អីចឹងអ្នកដឹកនាំទៅ

កៈ ប៉ុន្តែពេលណុងពូអាយុប៉ុន្មានដែរពូ?

ខៈ ពេលណុងខ្ញុំដូចជាអាយុ10ឆ្នាំលើសតិចតួចអីនឹង

កៈ ចឹងគេអោយពូធ្វើអីគេដែរទៅពូ?

ខៈ ខ្ញុំគេអោយទៅរែកដីដំបូក មានឃ្វាលគោ កាប់ដីដំបូកនឹង កាប់ដីដំបូកយកទៅចាក់ធ្វើជាជីអីនឹង

កៈ កាលពីជំនាន់ណុងពូនៅក្មេងចឹងជាកុមារមែនទេពូ?

ខៈ បាទនឹងហើយខ្ញុំនៅជាកុមារនឹង

កៈ ប៉ុន្តែពូគេអោយទៅកងកុមារមែនទេពូ?

ខៈ បាទគេអោយទៅកងកុមារនឹង

កៈ ចុះកងកុមារចឹងគេប្រើច្រើនម្ល៉េសពូ?

ខៈ នឹងដូចថាក្នុងបីទៅបួនទៅប្រាំខែអីចឹងគេអោយយើងទៅកាប់ដីនឹងរែកដីចឹង ហើយដល់ពេលដែរ រែកដីអីហើយចឹងទៅតាមខែ តាមរដូវគេចឹង ហើយពីរែកដីចឹងទៅគេអោយយើងទៅឃ្វាលគោអីចឹងទៅ ហើយដលល់ពេលដែររួចពីនឹងទៅគេអោយទៅកាបកន្តាំងខែតអីចឹងទៅ

កៈ បាទពូ ចុះរបបអាហាររបស់ក្មេង
នឹងរបបអាហាររបស់មនុស្សចាស់ខុសគ្នាយ៉ាងម៉េចដែរពូ?

ខៈ អានឹងជំនាន់ណុងគេចែក
ដល់ពេលម៉ោង11នឹងគេវៃជួងហើយដល់ពេលចឹងគេរត់ទៅរកអ្នកដាំស្ល
ហើយនឹងដល់ពេលចឹងគេចែកគ្នាចឹងទៅ គេចេកវែកដើម្បីទុកដួសមួយវែកម្នាក់ៗចឹងទៅ

កៈ ចឹងចាស់ក៏ប៉ុណ្ណឹងដែរពូ?

ខៈ ដូចថាចាស់ពីរវែករឺមួយក៏មួយវែកកន្លះអីចឹងទៅ

កៈ លក្ខណៈថាក្មេងមួយវែកចឹងទៅ?

ខៈ បាទក្មេងមួយវែកចឹង

កៈ ប៉ុន្តែក្មេងហូបគ្រាន់ដែរទេពូ?

ខៈ ទោះថាហូបមិនគ្រាន់ក៏ប្រាប់គេថាហូបគ្រាន់ដែរនឹង

កៈ ពីព្រោះគេមានតំរូវមានតែប៉ុណ្ណឹង?

ខៈ បាទគេតំរូវអោយតែប៉ុណ្ណឹងឯង តែបើយើងចង់តវ៉ាអីគេមានតែយកទៅវៃចោលនឹង

កៈ ចុះគេមានជំលាសពូទៅខេត្តណាផ្សេងទៀតទេ?

ខៈ ទៅដែរតែវាទៅមិនដល់ខេត្តទេ
ចង់និយាយថានៅក្នុងខេត្តនឹងដែរតែគ្រាន់តែឃុំខុសគ្នានឹងដូចថា
រំលងគ្នាពីរទៅបីភូមិចឹងណាស់

កៈ ចុះនៅនឹងពូធ្វើចឹង ចុះទៅកន្លែងផ្សេងពូធ្វើចឹងដែរ?

ខៈ ខ្ញុំត្រូវធ្វើចឹងដែរនឹង

កៈ ចឹងពូធ្វើចឹងដដែលហោសពូ

ខៈ គេអោយកាប់ដីដំបូកដាក់ស្រែ គេអោយឃ្វាលគោអីចឹងដែរនឹងខ្លះគេអោយដឹកបន្លែ
រឺមួយដឹករទេះគោអីនឹងទៅកន្លែងគេចឹងទៅ

កៈ ប៉ុន្តែទៅនឹងទៅជាលក្ខណៈក្មេងគ្នាយើងដដែលរឺម៉េចដែរពូ?

ខៈ បាទទៅក្មេងៗនឹង

កៈ ប៉ុន្តែទៅលក្ខណៈគ្នាយើងពីមុនទាំងអស់គ្នារឺម៉េចដែរពូ?

ខៈ អត់ទៅទាំងអស់ទេ
ដូចថាបែងចែកគ្នាដូចថាកន្លែងយើងមានប៉ុន្មានរទេះគោមានបួនប្រាំនឹមចឹងទៅ
អូនគេអោយក្មេងមានបួនប្រាំអ្នករឺមានប្រាំមួយនាក់ចឹងទៅកាន់រទេះគោទៅដឹកតាមភូមិអីចឹ
ងទៅណាស់

កៈ ដល់ពេលចឹងខាងនេះគេអោយធ្វើចឹងដែរទៅ?

ខៈ បាទគេអោយធ្វើចឹងដែរនឹង

កៈ អូ៎!គេធ្វើច្រើនដែរហោសពូ?

ខៈ គេចែកគ្នាមានក្រុម មានបក្សមានពួកអីចឹងទៅណាស់

កៈ ចុះបងប្អូនរបស់ពូគេអោយធ្វើអីទៅពូ?

ខៈ ប្អូនរបស់ខ្ញុំវាកើតមកឆ្នាំដែរយើងជិតចប់ហើយនឹងពេលដែរយើងរត់នឹង

កៈ បាទពូចុះម្តាយឪពុករបស់ពូគេអោយធ្វើអីគេដែរពូ?

ខៈ ម្តាយឪពុករបស់ខ្ញុំនឹង ម្តាយរបស់ខ្ញុំគេអោយកាប់ដីនឹងរែកដីចឹងដែរ
តែបើឪពុករបស់ខ្ញុំគេអោយទៅបររទេះគោនឹង

កៈ ប៉ុន្តែនៅទីណាដែរពូ?

ខៈ នៅភូមិយើងចំការរដ្ឋនឹងនៅជិតសាលាចំបក
អោយចូលភ្នំពេញអីចឹងទៅចូលម្តងរាប់ខែអីចឹង

កៈ អូ៎!យូរៗដែរហោពូ?

ខៈ
ដូចថារយៈពេលពីរខែទៅបីខែគេអោយទៅលេងផ្ទះមួយថ្ងៃចឹងទៅដឹកនេះដឹកនោះអីចឹង
ទៅ

កៈ បាទពូចុះពេលដែរដាច់ពលពតបានចូលខ្មែរក្រហមមែនទេពូ?

ខៈ បាទចូលខ្មែរក្រហមនឹង

កៈ ចុះដល់ពេលចឹងពូធ្វើអីគេដែរពូ?

ខៈ កាលណុងយើងចេះតែភ័យហើយចេះតែរត់ទៅនេះទៅនោះចេះតែគេចទៅណាស់
និយាយរួមនឹង យើងមិនសូវបានធ្វើនេះ
ធ្វើនោះទេយើងរស់តែគេចតែគ្រាប់នឹងនៅសម័យណុង

កៈ អូ៎!បាទចឹងណាពូ?

ខៈ យើងធ្វើស្រែឆ្លៀតដាំដំឡូងអីចឹងទៅក៏វាពិបាកវេទនាដែរនឹង

កៈ រហូតដល់ពេលដែរពូមានគ្រួសារនឹងពូគិតថាពូលំបាកអីគេដែរទៅពូ?

ខៈ ពេលមានគ្រួសារមកខ្ញុំដូចជាគ្មានការលំបាកអីទេ

កៈ ចឹងពូអត់មានការលំបាកអីទេ?

ខៈ នឹងហើយពីព្រោះតែយើងមានសិទ្ធិសេរីភាពអាចរកអីក៏បានដែរនឹង
យើងអាចធ្វើស្រែចំការអីបាន ដោយខ្លួនឯងហើយនឹងក្នុងការហូបចុកអីចឹងទៅ
អត់មានការលំបាកដូចនៅសម័យមុននឹងទេមានការលំបាកខ្លាំង

កៈ ប៉ុន្តែឥឡូវនឹងពូរៀងធូរបន្តិចហើយ?

ខៈ វារៀងធូរបន្តិចដែរនឹង

កៈ ចុះការលំបាកនឹងមានឧបសគ្គនឹងដូចជាពូជំនះវាដោយរបៀបណាដែរពូ?

ខៈ នឹងដូចថានៅសម័យពលពត
នឹងសម័យលុនណុលនឹងដូចខ្ញុំរៀបរាប់ប្រាប់ចឹងថាវាលំបាកប៉ុណ្ណាដែរ

កៈ ពូឆ្លងកាត់វាពុះពារឧបសគ្គណាពូ?

ខៈ ពីព្រោះខ្ញុំកើតមកបានទាន់ពីជំនាន់ដែរនឹងដែរ ទាន់សម័យយើងលុនណុល
នឹងសម័យយើងខ្មែរក្រហមនឹងណាស់

កៈ
ចុះពូគិតថាពេលណាដែរពូគិតថាជាពេលដែរពូសប្បាយនៅក្នុងឆាកជីវិតរបស់ពូចឹងណាស់
?

ខៈ ខ្ញុំសប្បាយជាងគេមានតែក្នុងឥឡូវនឹងទេ

កៈ អូ្!នៅក្នុងពេលឥឡូវនឹងហោសពូ?

ខៈ
បាទឥឡូវនឹងពីព្រោះថាយើងមិនចាំបាច់ថាយើងអត់មានរត់ហើយនឹងភ័យខ្លាចមានគ្រាប់ទេ អត់មានខ្លាចអីទាំងអស់យើងគិតតែខំប្រឹងរក បើយើងខំធ្វើយើងបាន

កៈ ចុះពូគិតថានៅពេលដែរពូមានចៅ
រឺមួយពេលដែរពូមានកូនចៅដែរធ្វើអោយពូសប្បាយចឹងណាស់មួយនឹងសប្បាយទេពូ?

ខៈ គ្មានអីនឹងអត់អីទេក្មួយ

កៈ ចឹងមួយនឹងក៏សប្បាយដែរពូ?

ខៈ មួយនឹងសប្បាយតើ

កៈ ចុះពូតាំងពីក្មេងពូធ្លាប់មានក្តីស្រម៉ៃថាពេលដែរពូធំឡើងពូចង់ធ្វើអីគេដែរទេពូ?

ខៈ ចង់ដែរប៉ុន្តែដូចថាព្រេងវាសនារបស់យើងកំនត់បានត្រឹមតែប៉ុណ្ណឹងឯង

កៈ ដូចជាកាលណុងពូចង់ធ្វើអីគេដែរពូ?

ខៈ ខ្ញុំកាលពីជំនាន់ណុងខ្ញុំដូចថាចង់ធ្វើជាជាងមាស
រឺជាជាងទងប៉ុន្តែគ្រាន់ថាវាយើងមិនអាចទៅដល់ ដោយសារតែម៉ែឪយើងវាក្រហាស
ចឹងទៅវាមិនរួចទេចឹងចេះតែតាមដំណើរចឹងទៅ

កៈ អូ្!ចេះតែចឹងទៅណាពូ?

ខៈ តែដល់ពេលឥឡូវនឹងវាហួសបាត់ទៅហើយនឹង

កៈ ចុះបើចង់អោយពូផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗតើពូចង់ផ្តែផ្តាំអីទៅពួកគាត់ដែរពូ?

ខ៖ រាល់តែថ្ងៃនឹងមានតែផ្ដែផ្ដាំអោយកូនខំប្រឹងរៀនសូត្រ ខំប្រឹងរក នឹងខំប្រឹងធ្វើចឹងទៅពីព្រោះតែឥឡូវ នឹងវាគ្មានសង្គ្រាមដូចសម័យមុននឹងទៀតទេ

ក៖ បាទត្រូវហើយពូ

ខ៖ ប៉ុន្ដែគ្រាន់តែសម័យឥឡូវនឹងកូនចៅវាពិបាកនិយាយស្ដាប់គ្នាណាស់មិនថាកូនគេ មិនថាកូនរបស់ខ្ញុំនឹងពិបាក

ក៖ ពិបាកយ៉ាងម៉េចទៅពូ?

ខ៖ វាដើរលេងភ្លើតភ្លើន វាដើរលេងសើចច្រើនចឹងទៅ អ្នកខ្លះកូនគេអ្នកខ្លះគេប្រើថ្នាំញៀនអីចឹងទៅណាស់

ក៖ អ៊ូ!ពូពិបាកជាងគេរឿងមួយនឹងហោសពូ?

ខ៖ បាទនឹងមិនមែនតែនៅក្នុងផ្ទះ នឹងក្រុមគ្រួសាររបស់ពូទេ ប៉ុន្ដែវាពិនិត្យទៅនៅក្នុងភូមិទាំងអស់នឹង

ក៖ បាទត្រូវហើយពូ

ខ៖ ចុះបើវាចឹងមែន

ក៖

ចុះពូមានអីចង់ផ្ដែផ្ដាំអីផ្សេងពីនឹងទៀតទេដូចថាលក្ខណះថាចង់អោយកូនចៅសំរេចនៅពីបំណង របស់ពូដែរកាលពីក្មេងពីមិនបានធ្វើវាអីទេ?

ខ៖

ចង់អោយវាខំរៀនសូត្រអោយបានចេះដឹងនឹងធ្វើការមានមុខមានមាត់នៅក្នុងការងារគេដែរនឹង ណាស់វាចឹង

ក៖ អ៊ូ!ចឹងណោះពូ?

ខ៖ បាទចេះតែផ្ដែផ្ដាំកូនចឹងទៅណាស់ ប្រាប់កូនថាធ្វើម៉េចឪធ្វើបានប៉ុណ្ណាចំណែកកូនឯងធ្វើម៉េចអោយ បានលើសឪណាស់ ប៉ុន្ដែកូនវាមិនតាមគោលបំណងរបស់យើងដែរនឹង

កៈ ដោយសារតែពូស្រលាញ់ជាងមាស ជាងម៉ូតូជាងអីចឹង ចឹងមានន័យថាគោលបំណងរបស់ពូចង់អោយកូនចៅបានសំរេចគោលបំណងមួយនឹងដែរណាពូ?

ខៈ ចង់អោយកូនចៅរៀនសូត្រតែបើចំពោះពូវារៀងអន់ជាងគេ ប៉ុន្តែបើប្អូនៗរបស់ពូវារៀងគ្រាន់បើវិញ ដល់ពេលសម័យក្រោយៗយើងមកគេខំប្រឹងរៀនដោយសារតែម៉ែឪចេះតែអោយប្អូនៗរៀនតទៅណាស់ ចឹងគេរៀនបានធ្វើពេទ្យ នឹងធ្វើជាគ្រូអីចឹងទៅ

កៈ ចឹងពូមានអីផ្សេងទៀតទេពូ?

ខៈ អត់ទេអត់មានអីទៀតផងក្មួយ

កៈ ចឹងជាចុងក្រោយអរគុណច្រើនពូដែរបានអោយខ្ញុំពិភាក្សាជាមួយពូដែរទាក់ទងពីប្រវត្តិរបស់ពូ ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាពូ

ខៈ បាទៗក្មួយ

កៈ បាទចឹងអរគុណច្រើនពូ៕៕៕